# រូបារម្មណ៍សិល្បៈក្នុងការតែងនិពន្ធស្នាដៃអក្សរសិល្ប៍



ដោយ ណុន សុខា
មន្ត្រីស្រាវជ្រាវនាយកដ្ឋានអក្សរសាស្ត្រនិងអក្សរសិល្ប៍
វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

ការតែងនិពន្ធអត្ថបទជាការងារដ៏លំបាកមួយ ទាមទារឱ្យអ្នកសរសេរត្រូវមានចំណេះដឹងទូលំទូលាយទាំងចំណេះដឹងទូទៅ ទាំងចំណេះជំនាញ។ គេតែងនិយាយថា ការអានសៀវភៅប្រៀបបានទៅនឹងការហែលទឹកតាមបណ្តោយខ្សែទឹកហូរ ឯការសរសេរ ការតែងនិពន្ធអត្ថបទប្រៀបបានទៅនឹងការហែលទឹកបញ្ច្រាសខ្សែទឹកហូរវិញ។

អ្នកនិពន្ធអក្សរសិល្ប៍ ជាបុគ្គលដែលត្រូវយល់ពីតម្រូវការនៃសង្គមមនុស្សក្នុងសម័យកាលរបស់គាត់ក៏ដូចជាក្នុងសម័យអតីតកាល ហើយក៏ត្រូវចេះរៀបចំអនាគតសម្រាប់មនុស្សទាំងពួងផងដែរ។ កាលណាអ្នកនិពន្ធបានធ្វើឱ្យអត្ថន័យនៃស្នាដៃរបស់ខ្លួនឆ្លើយតបក្នុងបរិបទទាំងបីនេះ អ្នកនិពន្ធនោះនឹងក្លាយទៅជាបុគ្គលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងអ្នកអាន។

ដើម្បីឆ្លើយតបទៅនឹងខ្លឹមសារខាងលើនេះ តើគ្រប់ស្នាដៃអក្សរសិល្ប៍ត្រូវបំពេញភាពចាំបាច់អ្វីខ្លះ?

ធាតុដ៏សំខាន់នៃអត្ថបទអក្សរសិល្ប៍ គឺអត្ថន័យនិងអត្ថរូប។ យើងត្រូវគិតថា តើអត្ថបទអក្សរសិល្ប៍មានតែអត្ថន័យ ហើយខ្វះអត្ថរូបបានទេ? ឬមានតែអត្ថរូប ហើយខ្វះអត្ថន័យបានទេ? ការសិក្សាអក្សរសិល្ប៍ គេតែងកំណត់ថា អត្ថរូបជាកញ្ចប់សម្រាប់ខ្ចប់ន័យ? ដូចនេះក្នុងអត្ថបទមួយ បើមានអត្ថន័យល្អ តែអត្ថរូបសោះកក្រោះ នោះការផ្សព្វផ្សាយក៏មិនជោគជ័យដែរ ឬថាបើមានតែអត្ថរូបល្អ ឯអត្ថន័យមិនល្អ ក៏គេមិនអាចឱ្យតម្លៃវាពេញលក្ខណៈបានដែរ។

ដូចនេះក្នុងវិធីនិម្មិតកម្មអក្សរសិល្ប៍ ដើម្បីឱ្យស្នាដៃមួយមានលក្ខណៈគ្រប់ជ្រុងជ្រោយ អ្នកនិពន្ធត្រូវតែយកចិត្តទុកដាក់ដូចគ្នា ទាំងផ្នែកអត្ថន័យនិងអត្ថរូបនៃអត្ថបទ។

ការលើកយកប្រធានបទ*រូបារម្មណ៍សិល្បៈក្នុងការតែងនិពន្ធស្នាដៃអក្សរសិល្ប៍*មកសិក្សានេះ ក្នុងគោលបំណងរកឱ្យឃើញថា តើរូបារម្មណ៍សិល្បៈមានអ្វីខ្លះ? ហើយអ្នកនិពន្ធមានវិធីបង្កើតរូបារម្មណ៍សិល្បៈយ៉ាងណាដែរ?

## ១- អ្នកនិពន្ធនិងស្នាដៃអក្សរសិល្ប៍

### ១.១- តើអ្នកនិពន្ធជានរណា?

អ្នកនិពន្ធ គឺជាអ្នកតែង រៀបរៀង ចងក្រងអត្ថបទ។

អ្នកនិពន្ធ មានដូចជា អ្នកនិពន្ធរឿងប្រលោមលោក អ្នកនិពន្ធប្រវត្តិសាស្ត្រ ជាដើម។

លក្ខណៈជាសារវន្តរបស់អ្នកនិពន្ធ គឺ***ទស្សនៈ*** ដែលមានអត្ថន័យទូលំទូលាយ។ អ្នកនិពន្ធជាបុគ្គលដែលមានទស្សនៈនិងចក្ខុវិស័យរបស់ខ្លួនផ្ទាល់ ដែលមើលឃើញ យល់ឃើញដោយខ្លួនឯងផ្ទាល់។ ជាងនេះទៅទៀត អ្នកនិពន្ធក៏ជាអ្នកហ៊ាននិយាយការពិតនូវអ្វីដែលគាត់បានមើលឃើញតាមរយៈការប្រើបច្ចេកទេសក្នុងការតែងនិពន្ធថែមទៀត។

បេសកកម្មរបស់អ្នកនិពន្ធ គឺត្រូវតែហ៊ាននិយាយនូវអ្វីដែលខ្លួនបានដឹងពិតប្រាកដ តែត្រូវចៀសវាងការអះអាងថា *ការយល់ដឹងរបស់ខ្លួននេះ ថាជាសច្ចធម៌ដាច់ខាត ពីព្រោះសច្ចធម៌វាមានការវិវត្តប្រែប្រួលជានិច្ច និងគ្មានអ្នកណាអាចអួតអាងថា ខ្លួនអាចក្តាប់បាននូវការវិវត្តនេះបានតាំងពីដើមរហូតដល់ចុងបញ្ចប់នោះទេ។*

គេតែងតែពោលថា អ្នកនិពន្ធក៏ដូចជាស្នាដៃអក្សរសិល្ប៍ គ្រាន់តែជាកញ្ចក់ឆ្លុះបញ្ចាំងឱ្យឃើញនូវសម័យកាលណាមួយតែប៉ុណ្ណោះ។ ត្រង់ចំណុចនេះ យើងក៏អាចបែងចែកអ្នកនិពន្ធទៅជាច្រើនប្រភេទដូចជាស្នាដៃអក្សរសិល្ប៍ដែរ ដែលមានអ្នកនិពន្ធតថនិយម(ប្រាកដនិយម) អ្នកនិពន្ធប្រលោមនិយម(អណ្តែតអណ្តូងនិយម) ជាដើម។

យ៉ាងនេះយើងឃើញថា អ្នកនិពន្ធមិនមែនគ្រាន់តែជាអ្នកចេះប្រើពាក្យពេចន៍ ឃ្លាល្បះក្នុងការទាក់ទាញអារម្មណ៍អ្នកអាន អ្នកស្តាប់ប៉ុណ្ណោះទេ។ ក្នុងវិស័យអក្សរសិល្ប៍ អ្នកនិពន្ធសរសេររឿងប្រលោមលោកដោយមានបង្កប់នូវទស្សនៈ ចក្ខុវិស័យ ដែលមានលក្ខណៈជាវិស្វករព្រលឹងថែមទៀតផង។

តួនាទីរបស់អ្នកនិពន្ធ គឺជាតួនាទីអ្នកធ្វើឱ្យមានការផ្លាស់ប្តូរ សម្រួបសម្រួលសណ្តាប់ធ្នាប់សង្គមឱ្យស័ក្តិសមទៅនឹងចំណង់ចំណូលចិត្តរបស់មហាជន ដើម្បីទាមទារសិទ្ធិសេរីភាព យុត្តិធម៌ក្នុងការរស់នៅ ជាដើម។

ទោះជាក្នុងករណីណាក៏ដោយ យើងអាចមើលឃើញថា អ្នកនិពន្ធមានទស្សនៈពីរប្រភេទគឺៈ

- អ្នកនិពន្ធមានទស្សនៈទុទិដ្ឋិនិយម អ្នកនិពន្ធប្រភេទនេះ មើលឃើញបញ្ហាទំនាស់ ជាក្រឹត្យក្រមដែលមិនអាចកែប្រែបាន ហើយយល់ថា វាជាកម្លាំងក្រៅក្រឹត្យក្រមរបស់ពិភពមនុស្សកត្តានេះធ្វើឱ្យអ្នកនិពន្ធប្រភេទនេះមិនរវល់ដោះស្រាយអ្វីដែរ។ អ្នកនិពន្ធប្រភេទនេះបង្កើតនូវពិភពមួយដែលគ្មានមូលដ្ឋានសមហេតុផលអ្វីសោះឡើយ។

- អ្នកនិពន្ធមានទស្សនៈសុទិដ្ឋិនិយម អ្នកនិពន្ធប្រភេទនេះ មានជំនឿជឿជាក់ថា*គ្មានអ្វីមានលក្ខណៈល្អប្រណីត គួរជាទីមនោរម្យដូចពិភពលោកនេះឡើយ រីឯមនុស្សក៏សុទ្ធតែមានលក្ខណៈគ្រប់គ្រាន់សម្រាប់ដឹកនាំគ្នាឆ្ពោះទៅរកសុភមង្គល ដោយចាប់ផ្តើមពីការកែប្រែសង្គម កែប្រែធម្មជាតិឱ្យកាន់តែមានលក្ខណៈល្អប្រសើរមួយថ្ងៃបន្តិចៗជាលំដាប់។ រីឯទំនាស់ដែលយើងមើលឃើញរាល់ថ្ងៃគ្រាន់តែជាបដិវាទកម្ម ដែលជំរុញឱ្យពិភពលោកឆ្ពោះទៅរកការរីកចម្រើនល្អតលាស់ជានិច្ចតែប៉ុណ្ណោះ។*

ទស្សនៈរបស់អ្នកនិពន្ធទាំងពីរប្រភេទនេះតែងផ្តល់នូវគតិសម្រាប់អ្នកសិក្សាពិចារណាហេតុផលទាំងឡាយដែលជាទំនាក់ទំនងគ្នារវាងសច្ចភាពជីវិតនិងសច្ចភាពសិល្បៈ ដើម្បីច្រោះយកនូវខ្លឹមសារជីវិតក្នុងការអប់រំក៏ដូចជាការអភិវឌ្ឍសង្គមផងដែរ។

### ១.២- ស្នាដៃអក្សរសិល្ប៍

បញ្ញត្តិ ***អក្សរសិល្ប៍*** គ្របសោបលើនិម្មិតកម្មទាំងឡាយដែលជាវប្បធម៌មនុស្សជាតិមួយចំនួន ដូចជា រឿងប្រលោមលោក រឿងព្រេង រឿងនិទាន(រឿងដែលគេសរសេរឬនិយាយប្រាប់) រឿងល្ខោន រឿងកុន រឿងវីដេអូ(រឿងដែលគេសម្តែងឱ្យមើល) និងស្នាដៃដែលមិនមែនជារឿង តែមានលក្ខណៈសិល្បៈ ដូចជា ចម្រៀង កំណាព្យ ពាក្យចួន ជាដើម។

ពាក្យថា***អក្សរសិល្ប៍***ត្រូវនឹងពាក្យ Littérature ជាភាសាបារាំង និង Literature ជាភាសាអង់គ្លេស ដែលពាក្យនេះមានឫសគល់ពីភាសាឡាតាំងថា Litterae (plural), Letter មានន័យថាសិល្បៈនៃស្នាដៃសំណេរ (the art of written works)។ ទោះបីជាពាក្យអក្សរសិល្ប៍ ឬ Littérature ឬ Literature ឬក៏ Litterae មានផ្សាំនឹងពាក្យអក្សរ (Letter) ក៏ដោយតាមទ្រឹស្តី គេចែកអក្សរសិល្ប៍ជាពីរគឺ***អក្សរសិល្ប៍តាមសម្តី*** (Littérature orale / Oral Literature) បច្ចុប្បន្នហៅថា អក្សរសិល្ប៍ប្រជាប្រិយ និង***អក្សរសិល្ប៍សំណេរ*** (Littérature écrite /Written Literature)។ ដោយសារបញ្ញត្តិនេះវាទាក់ទងនឹងពាក្យថា***រឿង***ដែលគេអាចរៀបរាប់ដោយការនិយាយផ្ទាល់មាត់ក៏បាន តាមរយៈការសរសេរក៏បាន ឬក៏បង្ហាញតាមការសម្តែងក៏បាន[១]។

ក្នុងភាសាខ្មែរយើងពាក្យ ***អក្សរសិល្ប៍*** នេះទើបត្រូវបានបង្កើតនៅក្នុងអំឡុងទសវត្ស

---

[១] សោម សុមុនី : ***វិភាគទានក្នុងការសិក្សាអក្សរសិល្ប៍ខ្មែរ*** ភ្នំពេញ, រោងពុម្ពម៉េងហាវ ឆ្នាំ២០១៥ ទំព័រទី១៨។

ឆ្នាំ១៩៦០ ដោយសាស្ត្រាចារ្យមួយក្រុម ដែលយល់ថា *គេគួរបំបែកពាក្យមួយទៀតចេញពី អក្សរសាស្ត្រ ពីព្រោះយោងទៅតាមភាសាសកល អក្សរសាស្ត្រ មានន័យថា ជាក្រុមមុខវិជ្ជាដ៏ធំមួយរួមមាន សង្គមវិជ្ជា ចិត្តវិទ្យា ទស្សនវិជ្ជា ភាសា ជាដើម* [២]។

តាមនិយមន័យសកល ពាក្យ ***អក្សរសិល្ប៍*** នេះ ត្រូវបានគេកំណត់ន័យច្រើនយ៉ាង ដោយយោងទៅតាមទស្សនៈផ្សេងៗ។ ទស្សនវិទូជនជាតិបារាំងឈ្មោះ ហ្សង់ ប៉ូលសាត (J.P. Sartre) បានកត់សម្គាល់ថា ចំពោះពាក្យ ***អក្សរសិល្ប៍*** គេត្រូវញែកយកន័យរបស់វាជាពីរផ្នែកសិន *គឺទីមួយ អក្សរសិល្ប៍ជារូបរាង (អក្សរ ពាក្យ ឃ្លា ។ល។) ទីពីរ* ***អក្សរសិល្ប៍*** *សំដៅយកន័យដែលជាការផ្គុំពាក្យពេចន៍ ឃ្លាឃ្លោង ទាំងនោះផ្តល់ឱ្យយើងជាអ្នកអាន។ ជាទូទៅ អក្សរសិល្ប៍ជាប្រភេទសិល្បៈដែលលាតត្រដាងទស្សនៈរបស់អ្នកនិពន្ធ ហើយក្នុងករណីនេះ វាជាកញ្ចក់ឆ្លុះបញ្ចាំងចក្រវាឡឬសង្គមមនុស្ស តាមការយល់ឃើញជាអត្តនោម័តរបស់អ្នកនិពន្ធម្នាក់ៗ។ តាមន័យខ្លះដែលមានលក្ខណៈបង្គួរ អក្សរសិល្ប៍ជាប្រភពនៃបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកនិពន្ធម្នាក់ៗ* [៣]។

ក្រៅពីនេះយើងក៏ឃើញមានការកំណត់និយមន័យ ***អក្សរសិល្ប៍*** ដោយយោងតាមលក្ខណៈសង្គមមនុស្សជាមូលដ្ឋាន ដូចជា៖

- លោក **កេង វ៉ាន់សាក់** យល់ថា *អក្សរសិល្ប៍គឺជាវិទ្យាស្យង់ដែលចោទនិងដោះស្រាយបញ្ហារបស់មនុស្សដោយសិល្បវិធីនិងតាមសង្គមនីមួយៗ។*
- **ឡេនីន** យល់ថា *ការអភិវឌ្ឍអក្សរសិល្ប៍ ជាដំណើរការលូតលាស់ជាក់ស្តែងខាងមនោគមវិជ្ជានិងសិល្បវិជ្ជា ដែលបានចូលរួមយ៉ាងសកម្មក្នុងការកែប្រែសង្គម ។*
- **ប៊ីយេលិនស្គី ដូប្រូលីយូបូវ និង ឆេនីឆូវស្គី** យល់ថា *សិល្បៈជាអាវុធសម្រាប់តស៊ូសង្គម ហើយអក្សរសិល្ប៍ជាកម្រងឯកសារសិក្សាពីជីវិត។*
- **គ័រគី** យល់ថា *អក្សរសិល្ប៍ គឺជាការសិក្សាពីមនុស្ស។*

ជារួមយើងអាចសន្និដ្ឋានបានថា *ការសិក្សាអក្សរសិល្ប៍ គឺជាការសិក្សាអំពីមនុស្សដើម្បីមនុស្ស។* ការសិក្សាអំពីមនុស្សគឺសិក្សាអំពីបញ្ហារបស់មនុស្ស ដែលមានបញ្ហាស្នេហា បញ្ហាសេរីភាព យុត្តិធម៌ អយុត្តិធម៌ ជាដើម, ឯដើម្បីមនុស្ស គឺដើម្បីអប់រំមនុស្ស អប់រំលើកកម្ពស់កម្រិតវប្បធម៌របស់មនុស្ស អប់រំសីលធម៌ ជាដើម។

---

[២] សូមមើល : ***កវី និង អក្សរសិល្ប៍*** នៅក្នុង : «ព្រឹត្តិប័ត្រស្រាវជ្រាវវិទ្យាសាស្ត្រ លេខ៤» ភ្នំពេញ, ឆ្នាំ១៩៨៧ ទំព័រទី៧៨-៧៩។

[៣] -ដ- ទំព័រទី៧៩។

**១.៣- លក្ខណៈពិសេសនៃអក្សរសិល្ប៍ខុសពីអត្ថបទដទៃ**

- បើប្រៀបធៀបនឹងសារព័ត៌មាន យើងឃើញថា ខ្លឹមសារអត្ថបទអក្សរសិល្ប៍មួយចំនួនហាក់ស្ថិតនៅដាច់ពីបញ្ហាប្រចាំថ្ងៃ ឯខ្លឹមសារសារព័ត៌មានយកចិត្តទុកដាក់លើពេលវេលាកំពុងប្រព្រឹត្តទៅ លើកយកបញ្ហាជាសារវន្ត និងជាសកលមកនិយាយ។ ខ្លឹមសារនៃអក្សរសិល្ប៍មិនបានគិតគូរពីពេលវេលាណាៗនោះទេ ទោះជាក្នុងអតីតកាល បច្ចុប្បន្នកាល អនាគតកាល សុទ្ធតែមានតម្លៃទាំងអស់។

ដូច្នេះបានជាស្នាដៃអក្សរសិល្ប៍បុរាណមួយចំនួនដែលកើតនៅក្នុងសម័យបុរាណ នៅតែមានតម្លៃខ្លាំងឬមានតម្លៃជាងស្នាដៃអក្សរសិល្ប៍នៃសម័យបច្ចុប្បន្នមួយចំនួនទៅទៀតក៏មាន ព្រោះវាបានរក្សាអមតភាពរបស់ខ្លួនជានិច្ច។ ម្យ៉ាងទៀតក្នុងការអត្ថាធិប្បាយ ការពណ៌នាអត្ថបទអក្សរសិល្ប៍ ត្រូវបានអ្នកនិពន្ធបញ្ចូលរូបារម្មណ៍ ច្នៃប្រឌិតតាមមនោគតិរបស់ខ្លួនបាន ចំណែកអត្ថបទសារព័ត៌មាន អ្នកនិពន្ធមិនអាចបញ្ចេញបញ្ចូលខ្លឹមសារនៃហេតុការណ៍តាមអារម្មណ៍របស់ខ្លួនបានទេ។ ដើម្បីឱ្យកាន់តែមានភាពជាក់លាក់អត្ថបទសារព័ត៌មានមានភ្ជាប់រូបថតនៃព្រឹត្តិការណ៍ថែមទៀតផង។

- ប្រៀបធៀបជាមួយអត្ថបទវិទ្យាសាស្ត្របច្ចេកទេស

អក្សរសិល្ប៍មិនផ្តល់អត្ថប្រយោជន៍ផ្ទាល់ដូចវិទ្យាសាស្ត្របច្ចេកទេសទេ។ អក្សរសិល្ប៍ហាក់មិនបានផ្លាស់ប្តូរ កែប្រែជីវភាពរស់នៅរបស់មនុស្សដោយផ្ទាល់ ជាក់ស្តែងភ្លាមៗទេ វាហាក់ដូចជាគ្មានលទ្ធភាពបំពេញតម្រូវការនៃជីវភាពឡើយ។ ឯអត្ថបទវិទ្យាសាស្ត្របច្ចេកទេសអាចនាំមកឱ្យមនុស្សនូវភាពធូរស្រាល ផាសុកភាព និងបំពេញតម្រូវការផ្នែកសម្ភារៈបានយ៉ាងពិតប្រាកដ។

អក្សរសិល្ប៍ជាដំណើរសំយោគប្រកបដោយលក្ខណៈជំនាញ ផ្តើមចេញពីភាពងាយស្រួលទៅភាពលំបាកស្មុគស្មាញប្រកបដោយសោភ័ណ។ ឯវិទ្យាសាស្ត្រធ្វើឱ្យមនុស្សងាកទៅរកភាពងាយស្រួល ប្រណីត និងឯកភាព។

អក្សរសិល្ប៍បានបំពេញបន្ថែមទៅលើវិទ្យាសាស្ត្រក្នុងការបណ្តុះបណ្តាលពុទ្ធិមនុស្ស។ វិទ្យាសាស្ត្របង្កើតវត្ថុទាំងឡាយក្នុងការបម្រើ ផ្តល់មធ្យោបាយសកម្មភាពដល់មនុស្ស ចំណែកឯអក្សរសិល្ប៍ផ្តល់នូវតម្លៃអប់រំសីលធម៌ គុណធម៌ ចំពោះមនុស្សនិងសង្គមមនុស្ស។

- ប្រៀបធៀបជាមួយទម្រង់ផ្សេងៗនៃសិល្បៈ អក្សរសិល្ប៍ដែលជាផ្នែកមួយនៃសិល្បៈដែរនោះ បានប្រើភាសាគ្រប់បែបយ៉ាងដោយយកចិត្តទុកដាក់ទៅលើតម្លៃពាក្យនីមួយៗ ឯទម្រង់នៃសិល្បៈមួយចំនួនវិញ ខ្លះក៏បានប្រើទម្រង់ផ្សេងៗ ដូចជា សូរសំឡេង ជាគំនូរ ជាពណ៌ ជាកាយវិការ ជាដើម។

និយាយរួមអក្សរសិល្ប៍ប្រើសំនួនវោហារ ជាមធ្យោបាយក្នុងការបង្ហាញអ្វីមួយ។

**១.៤- ហេតុអ្វីបានជាអ្នកនិពន្ធបង្កើតស្នាដៃអក្សរសិល្ប៍**?

- **ដើម្បីខ្លួនឯង**

អ្នកនិពន្ធមានបំណងរំដោះខ្លួនពីការឈឺចាប់ ទុក្ខព្រួយរបស់គាត់ ពោលគឺ *តាមរយៈស្នាដៃអក្សរសិល្ប៍ ជាមធ្យោបាយមួយ ដែលគេបានរកឃើញនូវខ្យល់ដកដង្ហើមបានស្រួល មិនសូវមានការលំបាកខាងផ្លូវចិត្ត នៅក្នុងពិភពលោកនិងមានការសប្បាយច្រើនចំពោះខ្លួនឯង។*

- **ដើម្បីមនុស្សទាំងពួង** អ្នកនិពន្ធសរសេរស្នាដៃរបស់ខ្លួនដើម្បីៈ

o ទាក់ទាញមនុស្សទាំងឡាយ ចែករំលែកនូវការឈឺចាប់របស់ខ្លួន។ គេតែងតែនិយាយថា *ស្នាដៃមួយជានិច្ចកាល ជាសម្រែកនៅក្នុងទីរហោស្ថាន ជាការលែងព្រាបដោយចងសារមួយភ្ជាប់នឹងជើងរបស់វា។*

o ចោទសួរដល់មនុស្សទាំងឡាយនូវបញ្ហាឬមតិយោបល់ផ្សេងៗ ក្នុងន័យបំភ្លឺនូវភាពងងឹត ស្រអាប់ដែលពិបាកយល់។

o បង្កើតពិភពប្លែកៗ ឆ្ពោះទៅរកគោលដៅតថៈ តែមិនមែនជាការឆ្លុះបញ្ចាំងតថៈឡើងវិញដោយឥតខ្ចោះឡើយ[៤]។

## ២- រូបារម្មណ៍សិល្បៈក្នុងការតែងនិពន្ធស្នាដៃអក្សរសិល្ប៍

អត្ថបទដែលល្អ គឺល្អទាំងអត្ថន័យផងនិងអត្ថរូបផង។ អត្ថន័យនិងអត្ថរូបជាអង្គពីរមិនអាចខ្វះណាមួយបានទេ ប្រសិនបើមានអត្ថន័យខ្វះអត្ថរូប ក៏មិនដឹងត្រូវផ្សព្វផ្សាយបែបណាដែរ ហើយបើអត្ថរូបល្អ តែអត្ថន័យមិនល្អ នោះអត្ថបទក៏ពុំមានលក្ខណៈពេញលេញដែរ។

អត្ថរូបដែលល្អទៅបានគឺដោយសារសិល្បវិធីតែងនិពន្ធរបស់អ្នកនិពន្ធ។ សិល្បវិធីតែងនិពន្ធនេះមានសារៈសំខាន់ណាស់ក្នុងការបំភ្លឺនិងបញ្ជាក់អត្ថន័យឱ្យបានច្បាស់លាស់។ សិល្បវិធីជាវិសេសភាពផ្ទាល់នៃមុខវិជ្ជាអក្សរសិល្ប៍ដែលធ្វើឱ្យអក្សរសិល្ប៍ខុសពីមុខវិជ្ជាដទៃទៀត។ តាមការសិក្សាយើងឃើញថា អត្ថបទប្រលោមលោកបុរាណ កវីនិពន្ធមានទេពកោសល្យខ្ពស់ចេះយកធម្មជាតិមកធ្វើជាកម្មវត្ថុក្នុងការបកស្រាយមនោសញ្ចេតនា បង្កើតបានតន្ត្រីភាពយ៉ាងអស្ចារ្យ។ ដូចនេះអ្វីដ៏សំខាន់ដែលអ្នកនិពន្ធស្នាដៃអក្សរសិល្ប៍ត្រូវមានគឺ ***សិល្បៈ*។** សិល្បៈនេះហើយដែលជួយបន្ថែមតម្លៃលើស្នាដៃតែងនិពន្ធឱ្យមានលក្ខណៈកាន់តែល្អប្រសើរនិងមាន

[៤] សូមមើល : ពៅ សាមី ***មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍និងសិល្បវិជ្ជា*** ភាគ១ ភ្នំពេញ, គ្រឹះស្ថានបោះពុម្ពសុភមង្គល ឆ្នាំ២០១២ ទំព័រទី៥-៦។

សោភ័ណថែមទៀត។ កិច្ចការណាដែលខ្វះសិល្បៈពុំអាចទាក់ទាញ ទទួលការពេញនិយម ឬ ស្ងើចសរសើរពីគ្រប់មជ្ឈដ្ឋានបានទេ។ យ៉ាងនេះ ដើម្បីក្លាយខ្លួនទៅជាកវី អ្នកនិពន្ធ ដែលទទួលការនិយមរាប់អាន ការស្ងើចសរសើរពីអ្នកអាន លុះត្រាតែកវី អ្នកនិពន្ធនោះចេះប្រើសិល្បវិធីតែងនិពន្ធខ្ពស់ក្នុងការភ្ញោចអារម្មណ៍អ្នកអានឱ្យរំភើបញាប់ញ័រដោយសារសំនួនវោហាររបស់ខ្លួន។ សំនួនវោហាររបស់កវី អ្នកនិពន្ធនេះហើយ ដែលធ្វើឱ្យអ្នកអានទទួលបាននូវរូបារម្មណ៍ផ្សេងៗ។

**២.១- តើរូបារម្មណ៍សិល្បៈជាអ្វី?**

រូបារម្មណ៍សិល្បៈជាទម្រង់នៃគំនិតក្នុងការឆ្លុះបញ្ចាំងតថភាព ដែលលេចរូបរាងឡើងជាផ្ទាំងរូបភាពនៃគំនិតនៃពិភពវត្ថុវិស័យ។ រូបារម្មណ៍សិល្បៈកើតឡើងនៅក្នុងញាណរបស់អ្នកនិពន្ធ ហើយអ្នកអានទទួលបានតាមរយៈស្នាដៃរបស់គាត់។រូបារម្មណ៍សិល្បៈ ត្រូវបានចាត់ទុកជាទម្រង់នៃចិត្តរំភើបក្នុងការបកស្រាយបាតុភូតទាំងឡាយតាមបែបវិចារណញ្ញាណ ដែលធាតុទាំងឡាយនៃទម្រង់ចិត្តរំភើបនោះ បានប្រមូលផ្តុំជាគំនិតបញ្ចូលទៅក្នុងការសម្តែងសំនួនវោហារ។ រូបារម្មណ៍សិល្បៈរមែងទទួលការវិនិច្ឆ័យជានិច្ចចំពោះបាតុភូតនិងទិដ្ឋភាពជាសារវន្តនៃតថភាព ដែលការវិនិច្ឆ័យនេះបង្កើតបានជាគំនិតសិល្បវិជ្ជាឬសិល្បមនោនៃស្នាដៃ។ ទស្សនៈនៃរូបារម្មណ៍សិល្បៈពឹងផ្អែកជាសំខាន់ទៅលើទ្រឹស្តីនៃការឆ្លុះបញ្ចាំង។

- ទ្រឹស្តីរូបធាតុនិយមបដិសំយោគប្រើពាក្យ *រូបារម្មណ៍* នេះជាការយល់ព្រមចំពោះការទទួលពុទ្ធិដ៏ទូលំទូលាយ។
- តាមទ្រឹស្តីឆ្លុះបញ្ចាំង *រូបារម្មណ៍* ត្រូវបានប្រដូចទៅនិងការផ្តិតចម្លង ការផ្តិតរូបភាពនៃគំនិតតថភាព។
- តាមទស្សនវិជ្ជា *រូបារម្មណ៍* ជាដំបូងគឺជាការឆ្លុះបញ្ចាំងបញ្ញាញាណនៃពិភពនៅជុំវិញ។
- តាមទ្រឹស្តីពុទ្ធិវិទ្យា *រូបារម្មណ៍* ជាការសម្តែងបង្ហាញនូវជីវិត អស្តិរូប ឥន្ទ្រិយារម្មណ៍ តំណាងអារម្មណ៍ ... ។

ហេតុនេះ រូបារម្មណ៍សិល្បៈលេចចេញឡើងជាទម្រង់ដោយឡែកមួយនៃការឆ្លុះបញ្ចាំងតថភាព។ គេអាចអនុវត្តតាមទ្រឹស្តីទស្សនវិជ្ជាទូទៅដោយកំណត់ថា *រូបារម្មណ៍សិល្បៈ គឺជាការសម្តែងបង្ហាញបែបប្រធានវិស័យនូវពិភពវត្ថុវិស័យ*[៥]។

តាមការសិក្សាយើងឃើញមានការកំណត់និយមន័យ និងការបែងចែកការប្រើពាក្យ

[៥] សូមមើល : ពៅ សាមី *មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍និងសិល្បវិជ្ជា* ភាគ២ ភ្នំពេញ, គ្រឹះស្ថានបោះពុម្ពសុភមង្គល ឆ្នាំ២០១២ ទំព័រទី៥០-៥២។

***រូបារម្មណ៍*** មានដូចតទៅ៖

- **រូបារម្មណ៍** រូបដែលកើតតាមរយៈអារម្មណ៍, អារម្មណ៍ដែលនាំឱ្យកើតជារូប[៦]។

- **រូបារម្មណ៍សិល្បៈ** ផ្ទាំងរូបភាពនៃគំនិតក្នុងស្នាដៃអក្សរសិល្ប៍ សិល្បៈ ដែលបង្កើតឡើងតាមរយៈគំនិតច្នៃប្រឌិត(សិល្បវិធី)របស់អ្នកនិពន្ធ សិល្បករ ឱ្យកើតឡើងជារូបរាង ជារឿងរ៉ាវ ជាដំណើររឿងអ្វីមួយ ដោយមានលក្ខណៈសមស្របទៅនឹងទិដ្ឋភាពសង្គម ធម្មជាតិណាមួយ ឬមានលក្ខណៈអច្ឆរិយៈក៏មាន។ ផ្ទាំងរូបភាពនៃគំនិតនេះផុសឡើងក្នុងអារម្មណ៍របស់អ្នកអាន អ្នកស្តាប់ អ្នកទស្សនា[៧]។

- **សិល្បារម្មណ៍** រូបារម្មណ៍សិល្បៈដែលកើតមានឡើងនៅក្នុងប្រធានអារម្មណ៍របស់អ្នកអាន អ្នកស្តាប់ អ្នកទស្សនា បន្ទាប់ពីមានការវិនិច្ឆ័យចំពោះរូបារម្មណ៍ថា ល្អឬមិនល្អ សមឬមិនសម ពីរោះឬមិនពីរោះ ជាដើម[៨]។

តាមនិយមន័យដូចបានកំណត់ខាងលើនេះ យើងឃើញថា***រូបារម្មណ៍*** គេប្រើក្នុងន័យទូទៅក៏បាន ក្នុងសិល្បៈក៏បាន។ ចំណែកឯពាក្យ***រូបារម្មណ៍សិល្បៈ*** គេប្រើសម្រាប់តែស្នាដៃអក្សរសិល្ប៍ សិល្បៈ ដែលបង្កើតឡើងដោយអ្នកនិពន្ធ សិល្បករ។ ចំពោះពាក្យ***សិល្បារម្មណ៍*** មានលក្ខណៈជ្រាលជ្រៅត្រង់ថា គេប្រើពាក្យនេះក្នុងន័យសិក្សារកតម្លៃសោភ័ណ គុណសម្បត្តិ គុណវិបត្តិ ភាពពីរោះ មិនពីរោះ ល្អ អាក្រក់ ជាដើម នៃសិល្បៈ។ ពាក្យ***សិល្បារម្មណ៍*** *ជាបាតុភូតដែលមានចំពោះតែមនុស្សដែលមានសកម្មភាពផ្នែកសម្បជញ្ញៈខ្លាំងប៉ុណ្ណោះទេ ព្រោះវាជាបាតុភូតដែលកើតមានឡើងតែក្នុងអារម្មណ៍របស់មនុស្ស*[៩]។

### ២.២- រូបារម្មណ៍សិល្បៈក្នុងស្នាដៃអក្សរសិល្ប៍

តាមការសិក្សាកន្លងមក ចំពោះរូបារម្មណ៍ក្នុងអត្ថបទអក្សរសិល្ប៍ ដែលយើងកំណត់ថា ***រូបារម្មណ៍សិល្បៈ*** នេះមានពីរប្រភេទគឺ*រូបារម្មណ៍សុទ្ធៗដែលមាននៅក្នុងកំណាព្យ ហៅថា* ***រូបារម្មណ៍ក្នុងកំណាព្យ*** *និងរូបារម្មណ៍ដែលមានលក្ខណៈក្នុងការតែងនិពន្ធ ហៅថា* ***រូបារម្មណ៍វិធី ឬវិធីបង្កើតរូបារម្មណ៍***[១០]។

---

[៦] សទ្ទានុក្រម ***ភាសាវិទ្យានិងអក្សរសិល្ប៍*** ខ្មែរ-អង់គ្លេស-បារាំង, ភ្នំពេញ, បោះពុម្ពដោយក្រុមប្រឹក្សាជាតិភាសាខ្មែរ ឆ្នាំ២០១៣ ទំព័រទី៩០។

[៧] ***ក្រុមប្រឹក្សាជាតិភាសាខ្មែរ*** អនុម័តថ្ងៃអង្គារ ទី១២ ខែកុម្ភៈ ឆ្នាំ២០១៩។

[៨] ***ក្រុមប្រឹក្សាជាតិភាសាខ្មែរ*** អនុម័តថ្ងៃអង្គារ ទី១២ ខែកុម្ភៈ ឆ្នាំ២០១៩។

[៩] សូមមើល : «ព្រឹត្តិប័ត្រស្រាវជ្រាវវិទ្យាសាស្ត្រ លេខ២» នៅក្នុង :***សិល្បារម្មណ៍សាស្ត្រ ម៉ាក្សនិយម*** ភ្នំពេញ, ឆ្នាំ១៩៨៧ ទំព័រទី៥៣-៥៥។

[១០] លាង ហាប់អាន : ***សិក្សាអត្ថបទ*** ភាគ២ ភ្នំពេញ, រោងពុម្ព [?] ឆ្នាំ១៩៦៦ ទំព័រទី១៦៨។

វិធីបង្កើតរូបារម្មណ៍ក្នុងអត្ថបទអក្សរសិល្ប៍ ជាផ្នែកមួយនៃអត្ថរូប ជាការនិពន្ធទូទៅដែលមានន័យចំពោះការសរសេររៀបរាប់ធ្វើឱ្យអត្ថបទមានសម្ផស្ស មានរសជាតិ ជាទីទាក់ទាញ ចាប់អារម្មណ៍នៃប្រធានអារម្មណ៍របស់អ្នកអាន។

នៅក្នុងអត្ថបទអក្សរសិល្ប៍ខ្មែរ កវី អ្នកនិពន្ធ តែងតែបង្កើតរូបារម្មណ៍សំខាន់ៗ តាមរយៈពាក្យពេចន៍ ឃ្លាល្បះ ឱ្យមានសម្ផស្សទាក់ទាញអារម្មណ៍របស់អ្នកអាន អ្នកស្ដាប់ អ្នកទស្សនា តាមទ្វារនៃវិញ្ញាណផ្សេងៗមាន ភ្នែក ច្រមុះ ត្រចៀក អណ្ដាត ស្បែក ចិត្ត គំនិត បញ្ញា ជាដើម។

ជាទូទៅគេចែករូបារម្មណ៍សិល្បៈជា៤គឺ៖

**ក- ជីវរូបារម្មណ៍**

ជីវរូបារម្មណ៍ជារូបារម្មណ៍សិល្បៈកើតឡើងដោយកវី អ្នកនិពន្ធប្រើពាក្យពេចន៍ធ្វើឱ្យវត្ថុឥតជីវិត ឥតចេតនា ឥតវិញ្ញាណ ប្រែក្លាយហាក់ជាមានជីវិត មានចេតនា មានវិញ្ញាណ មានចលនារស់រវើកឡើង។

ជីវរូបារម្មណ៍អាចបង្កើតតាមការប្រៀបធៀបផ្ទួផ្ទងវត្ថុពីរ ដោយយកពាក្យសម្គាល់វត្ថុទាំងនោះមកដាក់ជិតគ្នាភ្ជាប់គ្នា ដោយពុំចាំបាច់ប្រើពាក្យបច្ច័យដូចឧបមានរូបារម្មណ៍ឡើយ។

ជីវរូបារម្មណ៍ជាកន្សោមគោលការណ៍ច្នៃប្រឌិតទាំងឡាយដែលកំណត់ដល់ការជ្រើសសម្រាំង ការសំយោគ តំណាងហេតុការណ៍ និងបាតុភូតនៃជីវិតជារូបារម្មណ៍សិល្បៈ។ វិធីច្នៃប្រឌិតនេះផ្សារភ្ជាប់ជិតស្និទ្ធទៅនឹងគោលការណ៍ជាសារវន្តទាំងឡាយនៃទស្សនៈសង្គមប្រចាំសម័យកាល។

ឧទាហរណ៍ *សម្ដីផ្អែម ចិត្តទន់ ខ្យល់ត្អូញឆ្លងឆ្លើយ ផ្គរគ្រហឹម រលកបោកប្រាណ ...។*

**ខ- ឧបមានរូបារម្មណ៍**

ឧបមានរូបារម្មណ៍ជារូបារម្មណ៍សិល្បៈដែលកើតឡើងដោយកវី អ្នកនិពន្ធចេះប្រើពាក្យពេចន៍ផ្ទួផ្ទង ប្រៀបធៀបវត្ថុមួយទៅវត្ថុមួយទៀត ដើម្បីបង្ហាញនូវភាពស្របគ្នា ដូចគ្នា ភាពខុសប្លែកគ្នា ជាដើម។ ការផ្ទួផ្ទង ប្រៀបធៀបនេះអ្នកនិពន្ធប្រើពាក្យបច្ច័យ *ធ្លាក់*សម្រាប់ប្រៀបផ្ទឹម ដែលពាក្យទាំងនោះមាន *វូ រូបហាន ដូច ដូចជា ប្រៀបបាននឹង ប្រៀបដូច ហាក់ដូច ឧបមា ...។* ក្រៅពីពាក្យសម្រាប់ធៀបនេះ យើងឃើញនៅមានពាក្យមួយចំនួនទៀត ដែលកវី អ្នកនិពន្ធបានប្រើដូចជា *គឺ ជា យ៉ាងណា ... យ៉ាងនោះ ។*

យើងអាចចែកឧបមានរូបារម្មណ៍ជា៖

- ឧបមានរូបារម្មណ៍ដែលកើតឡើងដោយការប្រើពាក្យសម្រាប់ប្រដូច មានពាក្យ *វូ រូបហាន ដូច ដូចជា ប្រៀបបាននឹង ប្រៀបដូច ហាក់ដូច ឧបមា ...។*

ឧទាហរណ៍ ក្នុងរឿងទុំទាវ

[...] ខ្លួនប្អូនសព្វថ្ងៃប្រៀបដូចផ្កា　　ឯអ្នកឧបមាដូចកន្លង់
ហើរមកឃើញផ្កាចូលត្រឹបត្រង់　　រួចមិនបង្អង់ត្រាច់លីលា។
ទុំថាខ្លួនបងដូចរាជសីហ៍　　ខ្លួននាងទាវស្រីដូចគុហា
រាជសីហ៍បើបានលំនៅជា　　មិនឱ្យឃ្លាតឃ្លាគុហាឡើយ។
ទាវថាខ្លួនប្អូនដូចកំពង់　　ខ្លួនអ្នកឆោមយង់ដូចទូកហើយ
ចាប់ចតអាស្រ័យអ្នកថ្លៃអើយ　　ចេញទៅកន្តើយមិននឹកនា។
ទុំថាឱបងដូចត្រីធំ　　ខ្លួនទាវក្រមុំដូចគង្គា
ត្រីបានទឹកជ្រៅហែលរេរា　　កុំកែវពុំងាគិតសង្ស័យ[១១]។ [...]

- ឧបមានរូបារម្មណ៍ដែលកើតពីការប្រើពាក្យបច្ច័យពិសេសមួយចំនួនទៀត ដូចជា *គឺ ជា យ៉ាងណា...យ៉ាងនោះ។*

  - ការប្រើពាក្យ «គឺ» សម្រាប់បង្កើតនូវឧបមានរូបារម្មណ៍ នៅពេលដែលគេប្រៀបធៀបវត្ថុឬមតិពីរ ដែលប្លែកគ្នា មានន័យផ្ទុយគ្នា មិនទាក់ទងនឹងគ្នា។ ការប្រើវិធីប្រដូចដែលមិនដូចគ្នានេះ ធ្វើឱ្យអ្នកអានភ្ញាក់អារម្មណ៍បង្កើតនូវការត្រិះរិះ ពិចារណា គឺកើតនូវរូបារម្មណ៍នេះឯង។

  ឧទាហរណ៍　រស់គឺស្លាប់ រស់គឺសង្ឃឹម ព្រឹកគឺក្រពះ...។

  [...] រស់គឺប្រាថ្នា　សង្ឃឹមចេតនា　រាល់រូបរាងកាយ
  ទោះបានក្រីក្រ បានអរបានស្តាយ ព្រួយឬសប្បាយ
  សង្ឃឹមទៀតដែរ[១២]។[...]

  - ការប្រើពាក្យបច្ច័យ «ជា» ពាក្យនេះគេប្រើសម្រាប់ប្រៀបប្រដូចផលនៃវត្ថុមួយ ដែលកើតមកអំពីហេតុនៃវត្ថុមួយទៀត។

  ឧទាហរណ៍ [...] កើតស្លាប់ទៅមក ដូចទឹករលក អន្ទោលតាមគ្នា
  មួយងើបលិចទៅ ឥតនៅរេរា មួយទៀតងើប*ជា*
  រលកផលកម្ម[១៣]។[...]

---

[១១] ព្រះបទុមត្ថេរ សោម : ***រឿងទុំទាវ*** ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៧ ឆ្នាំ១៩៧១ ទំព័រទី៥៣។

[១២] កេង វ៉ាន់សាក់ : ***តុកកាមកិលេស*** ភ្នំពេញ, រោងពុម្ព [?] ឆ្នាំបោះពុម្ព [?] ទំព័រ «ខ»។

[១៣] - ដ - ទំព័រទី៨១។

- ការប្រើពាក្យ «យ៉ាងណា ... យ៉ាងនោះ» ពាក្យនេះប្រើសម្រាប់ប្រដូចវត្ថុដែលមានលក្ខណៈដូចគ្នាតាមលំនាំសភាវៈ ឬការប្រព្រឹត្តិទៅដូចគ្នា។

ឧទាហរណ៍ [...] ទឹកហូរយ៉ាងណា យ៉ាងនោះលោកា ប្តូរកាយប្តូរចិត្ត
គ្មានអ្វីនៅនឹង វិលវឹងជាប់ស្អិត បើជាប់ប្រកិត
គឺប្តូរនេះឯង[១៤]។ [...]

**គ- និមិត្តរូបារម្មណ៍**

និមិត្តរូបារម្មណ៍ជារូបារម្មណ៍សិល្បៈដែលកើតឡើងដោយកវី អ្នកនិពន្ធចេះយកសញ្ញាភាពមកប្រើដើម្បីសម្គាល់មតិ ទស្សនៈ ឬបកស្រាយនូវគំនិតឬទស្សនៈអ្វីមួយ។

ក្នុងក្របខណ្ឌវប្បធម៌សិល្បៈ និមិត្តរូបារម្មណ៍មានលក្ខណៈជាការសន្មត និងមានទម្រង់ស្រដៀងគ្នានឹងសញ្ញា ប៉ុន្តែខុសប្លែកពីសញ្ញាត្រង់ថា និមិត្តរូបារម្មណ៍រក្សាទុកនូវតម្លៃ និងអនុភាពមួយក្នុងការសម្តែងបង្ហាញ។

និមិត្តរូបារម្មណ៍កើតមាននៅក្នុងអត្ថបទកំណាព្យឬអត្ថបទពាក្យរាយ ដែលអ្នកនិពន្ធរៀបរាប់អធិប្បាយពីគោលបំណងអ្វីមួយដើម្បីបង្ហាញនូវមតិយោបល់ ទស្សនៈណាមួយ។

និមិត្តរូបារម្មណ៍ជួនកាលស្ថិតនៅក្នុងអត្ថបទទាំងមូល ជួនកាលស្ថិតនៅក្នុងផ្នែកមួយនៃអត្ថបទ តាមរយៈការលើកយកពាក្យពេចន៍មកប្រើដើម្បីក្នុងការបង្ហាញមតិយោបល់ ទស្សនៈណាមួយនោះ។

ឧទាហរណ៍

- **និមិត្តរូបារម្មណ៍ក្នុងរឿង ដូចជា៖**
  - រឿងចចកនិងកូនចៀម
  - រឿងស្រមោចនិងរៃ
  - រឿងចចកនិងក្អែក ជាដើម។
- **និមិត្តរូបារម្មណ៍ក្នុងការប្រើពាក្យពេចន៍**
  - **ពន្លឺ** សម្គាល់នូវវិជ្ជា បញ្ញា
  - **ព្រាបស** សម្គាល់នូវសន្តិភាព
  - **ក្បាលខ្មោចនិងឆ្អឹងស្មងជើងខ្វែងគ្នាពីរ** សម្គាល់នូវគ្រោះថ្នាក់ដល់ជីវិត
  - **ចិញ្ចៀន** តំណាងនូវពាក្យសន្យា ចិត្តភក្តីភាព

[១៤] កេង វ៉ាន់សាក់ : *គុកកាមកិលេស* ដ.ឯ.ម. ទំព័រទី៧៧។

- **ច្រវាក់ខ្នោះឃ្នាង** តំណាងនូវការជិះជាន់ ការចាប់ចង
- **ពណ៌នីមួយៗ** តំណាងន័យសេចក្ដីមួយ តាមការកំណត់របស់ជាតិនីមួយៗ។

ឧទាហរណ៍

- **ពណ៌ក្រហម** សម្គាល់នូវទឹកចិត្តឬសេចក្ដីស្នេហាដ៏លើសលប់ នូវជំនឿស៊ប់ចំពោះឧត្ដមគតិអ្វីមួយ នូវសេចក្ដីអង់អាចក្លាហាន នូវលទ្ធិឬមនោគមវិជ្ជាកុម្មុយនីស្ដនិយម។
- **ពណ៌បៃតង** សម្គាល់នូវសេចក្ដីសង្ឃឹម
- **ពណ៌ខៀវ** សម្គាល់នូវមេត្រីភាពឬតម្លៃផ្លូវចិត្តរបស់តួអង្គ
- **ពណ៌ស្វាយ** សម្គាល់នូវភក្ដីភាព ចិត្តស្មោះត្រង់ តម្លៃចំណេះវិជ្ជា
- **ពណ៌លឿង** សម្គាល់នូវការបែកបាក់ ការផិតក្បត់ប្ដីប្រពន្ធ ការលែងលះប្ដីប្រពន្ធ ការអស់សង្ឃឹម (តាមជំនឿនិយមរបស់ជនជាតិអឺរ៉ុប)។ ប៉ុន្តែចំពោះជនជាតិអាស៊ីវិញ ពណ៌លឿងនេះសម្គាល់នូវការជ្រះថ្លា ស្ងប់ស្ងាត់ខាងផ្លូវកាយ វាចា ចិត្ត។
- **ពណ៌ស** សម្គាល់នូវសេចក្ដីបរិសុទ្ធ ផូរផង់ នូវសន្តិភាព ការស្ងប់ក្នុងចិត្ត
- **ពណ៌ខ្មៅ** សម្គាល់នូវទុក្ខសោក ការព្រួយបារម្ភ ភាពអាក្រក់ កាចសាហាវ អស់សង្ឃឹម។

### ឃ- រូបារូបិយារម្មណ៍

រូបារូបិយារម្មណ៍ជារូបារម្មណ៍សិល្បៈមាននៅក្នុងវគ្គនីមួយៗ ឬនៅក្នុងអត្ថបទទាំងមូលដែលកវី អ្នកនិពន្ធបង្កើតឡើងតាមរយៈការប្រើពាក្យពេចន៍ ឃ្លាល្បះ បង្ហាញនូវអ្វីមួយជាប់ទាក់ទងទៅនឹងអង្គវិញ្ញាណ ចេតនា បញ្ញា អារម្មណ៍របស់មនុស្ស ពោលគឺៈ

- រូបារម្មណ៍ ទាក់ទងនឹងឥន្ទ្រីយ៍ ហៅថា ឥន្ទ្រីយ៍រូបារម្មណ៍
- រូបារម្មណ៍ ទាក់ទងនឹងផ្លូវចិត្តបង្កើតជាកាមតម្រេក កាមរាគៈ ហៅថា កាមរូបារម្មណ៍
- រូបារម្មណ៍ ធ្វើឱ្យចិត្តញាប់ញ័រ រំភើប ចូលចិត្ត ជាប់ចិត្ត ហៅថា ចេតនារូបារម្មណ៍
- រូបារម្មណ៍ទាក់ទងនឹងស្មារតីភ្ញាក់រព្លក ពិចារណា ហៅថា មនោឬបញ្ញារូបារម្មណ៍។

### ឃ.១- ឥន្ទ្រីយ៍រូបារម្មណ៍

ឥន្ទ្រីយ៍រូបារម្មណ៍ជារូបារម្មណ៍សិល្បៈដែលកើតឡើងតាមរយៈពាក្យពេចន៍ ឃ្លាល្បះរបស់កវី អ្នកនិពន្ធធ្វើឱ្យរំភើប រំញោចដល់អង្គឥន្ទ្រីយ៍ណាមួយមាន ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ ជាដើម។

• **ចក្ខុរូបារម្មណ៍** ជារូបារម្មណ៍សិល្បៈដែលកើតឡើងតាមរយៈពាក្យពេចន៍ ឃ្លាល្បះរបស់កវី អ្នកនិពន្ធ ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ មានអារម្មណ៍រំភើប ផ្ចិតផ្ចាប់នឹងអ្វីមួយ ហាក់ដូចបានឃើញច្បាស់នឹងភ្នែកនូវរូបរាង ហេតុការណ៍ ដូចជាមើលជាក់ច្បាស់នឹងភ្នែកផងដែរ។

ឧទាហរណ៍ វគ្គមួយនៃបទចម្រៀង***រំដួលដងស្ទឹងសង្កែ***របស់លោក គង្គ ប៊ុនឈឿន

[...] *អូនដើរវើសគ្រាំ ក្នុងស្ទឹងសង្កែ ភ័ក្ត្រដូចដួងខែ ថ្ពាល់ខួចមានស្នេហ៍ នេត្រាពណ្ណរាយ*

*ហត្ថាខ្ចីល្អក់ សក់ខ្មៅរំសាយ ល្អគន់មិនណាយ ក្លិនខ្លួនឆោមឆាយ រាយសំណាញ់ស្នេហ៍។* [...]

• **សោតរូបារម្មណ៍** ជារូបារម្មណ៍សិល្បៈដែលកើតឡើងតាមរយៈពាក្យពេចន៍ ឃ្លាល្បះរបស់កវី អ្នកនិពន្ធ បង្កើតបានជាសូរសំឡេងចួនរណ្ដំនៃស្រៈឬព្យញ្ជនៈ ស្របទៅនឹងសម្រែកសត្វ សំឡេងធម្មជាតិ ដូចជា សូរសម្រែកសត្វ សំឡេងផ្គរលាន់ ស្នូររន្ទះ សំឡេងខ្យល់ ស្នូរព្យុះសង្ឃរា ស្នូរទឹកភ្លៀង ជាដើម ដែលសំឡេងទាំងនោះធ្វើឱ្យសោតវិញ្ញាណរបស់អ្នកអាន អ្នកស្ដាប់រំភើប បង្កើតបាននូវសោតរូបារម្មណ៍។

ឧទាហរណ៍

| | |
|---|---|
| សូរសំឡេងត្រាប់តាមសត្វ | *ឆ្មាស្រែកម៉េវ ឆ្កែលូវ៉ូៗ ជ្រូកស្រែកអ៊ូកៗ មាន់រងាវ កុកគីកែកឹត ទាស្រែកកាបៗ ...។* |
| សំឡេងត្រាប់តាមធម្មជាតិ | *ផ្គរលាន់ឮសូរក្ខុងៗ រន្ទះបាញ់ផាំង ភ្លៀងស្រក់ស្រឹបៗ ទឹករលកគ្រាំងៗ ខ្យល់បក់វ៉ូៗ ...។* |

សំឡេងស្រៈ ព្យញ្ជនៈចួនផ្ទួនរណ្ដំគ្នា ឧទាហរណ៍ ក្នុងរឿងរាមកេរ្ដិ៍ ខ្សែទី៣ ទំព័រ២០

*ខុនខែង ខឹងខ្ញួន ខឹងខាំ មាត់ភ្ញាំង៉ាំង៉ុាំ ត្របាក់ត្របែងផ្លែងកាំ។*

*កោះសរសក្តិផ្លែងបីទន្ទាំ ខុនចក្រព្រះហត្ថស្តាំ គ្រវីគ្រវាសបោះបាច។*

• **ឃាន និង ជីវ្ហារូបារម្មណ៍** ជារូបារម្មណ៍សិល្បៈដែលកើតឡើងដោយកវី អ្នកនិពន្ធចេះប្រើពាក្យពេចន៍ ឃ្លាល្បះក្នុងការរៀបរាប់ ពណ៌នារំលេចឱ្យអ្នកអាន អ្នកស្ដាប់ហាក់បានទទួលក្លិនក្រអូប ឈ្ងុយ ឆ្អេះឆ្អាប... ឬបានទទួលរសជាតិ ផ្អែម ប្រៃ ល្វីងជូរចត់ ជាដើម។

• **កាយរូបារម្មណ៍** ជារូបារម្មណ៍សិល្បៈដែលកើតឡើងកវី អ្នកនិពន្ធចេះប្រើពាក្យពេចន៍ ឃ្លាល្បះក្នុងការពណ៌នា រៀបរាប់ ធ្វើឱ្យអ្នកអាន អ្នកស្ដាប់មានការរំភើបញាប់ញ័រដល់កាយិន្ទ្រិយ៍។ កាយរូបារម្មណ៍កើតឡើងតាមអារម្មណ៍ដឹងនូវ*ភាពរលីង រលោង ទន់ភ្លន់ ស្រលូន ក្តៀវក្លំ ក្ដៅត្រជាក់ ច្រូងច្រាង រៀវឆ្អារ* ជាដើម។

**ឃ.២- កាមរូបារម្មណ៍**

កាមរូបារម្មណ៍ជារូបារម្មណ៍សិល្បៈដែលកើតឡើងដោយកវី អ្នកនិពន្ធចេះប្រើពាក្យ

ពេចន៍ ឃ្លាល្បះក្នុងការរៀបរាប់ ពណ៌នានូវទឹកចិត្តស្នេហា តាមរយៈការប្រើពាក្យផ្អែមល្ហែម លួងលោម ថ្នាក់ថ្នម ដូចជា *អូន កែវជីវ៉ា កែវព្រលឹង ព្រលឹងជីវិត ព្រលឹងមាសស្នេហ៍ ដួងជីវិត ស្ងួន នួននាង បងបណ្ដូលចិត្ត បណ្ដូលជីវិត ជាដើម* ឬប្រើពាក្យពេចន៍ដែលសម្គាល់នូវដំណើរចិត្ត ចលនា កាយវិការផ្សេងៗ ដែលមានក្នុងសេចក្ដីស្នេហា ក្នុងន័យបញ្ឆិតបញ្ឆៀង ធ្វើឱ្យអ្នកអាន អ្នកស្ដាប់យល់ថាជាកាមចលនាដោយខ្លួនឯង។

ឧទាហរណ៍ [...] គ្រុឧបីក្រសោប ត្រកងអង្គឱប អង្អែលអស់ប្រាណ
មូលមិចថៃថើប សំរើបសម្រាន្ត ផ្ទុំផ្ទឹមផ្ទាល់មាន
ចិត្តចងមេត្រី។
រួមរក្សរសរូប ក្រអែបក្រអូប ផ្សាយផ្សព្វឥន្ទ្រិយ
ស្រើបស្រួលមូលមិត្ត ជួញជិតប្រតី- ព័ទ្ធពេញបេតី
សុខសេពចំណង់[១៥]។ [...]

### ឃ.៣- ចេតនារូបារម្មណ៍

ចេតនារូបារម្មណ៍ជារូបារម្មណ៍សិល្បៈដែលកើតឡើងដោយកវី អ្នកនិពន្ធចេះពាក្យពេចន៍ ឃ្លាល្បះក្នុងការរៀបរាប់ ពណ៌នា បំផុសនូវមនោសញ្ចេតនា ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ទទួលអារម្មណ៍ *ទុក្ខព្រួយ រីករាយសប្បាយ កំហឹង ការភ័យខ្លាច ត្រេកត្រអាល ស្រឡាញ់ ស្អប់ ច្រណែន ប្រច័ណ្ឌ អាលោះអាល័យ សោកស្ដាយ សង្ឃឹម អស់សង្ឃឹម ឬ បំផុសនូវជំនឿចំពោះលទ្ធិនយោបាយ សាសនា មនោគមវិជ្ជាណាមួយ។*

### ឃ.៤- មនោឬបញ្ញារូបារម្មណ៍

មនោឬបញ្ញារូបារម្មណ៍ជារូបារម្មណ៍សិល្បៈដែលកើតឡើងដោយកវី អ្នកនិពន្ធចេះប្រើពាក្យពេចន៍ ឃ្លាល្បះ ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ កើតនូវការត្រិះរិះ ពិចារណា ពិភាក្សា សង្កេត ធ្វើឱ្យសញ្ចេតនារបស់ប្រធានអារម្មណ៍រំភើបញាប់ញ័រ។

សរុបមករូបារម្មណ៍សិល្បៈជាមធ្យោបាយតែមួយគត់ក្នុងការឆ្លុះបញ្ចាំងតថភាពក្នុងស្នាដៃអក្សរសិល្ប៍ សិល្បៈ។ ទោះបីរូបារម្មណ៍សិល្បៈត្រូវបានបង្កើតឡើងតាមគោលការណ៍រួមឬរូបមន្តរួមយ៉ាងណាក្ដី ក៏ការអនុវត្តរបស់អ្នកនិពន្ធតែងមានល្បិចរស់រវើក បង្កើតបានជាទម្រង់រូបារម្មណ៍ប្លែកៗគ្នា។ រូបារម្មណ៍សិល្បៈត្រូវបានកំណត់ថាជាព្រលឹងរបស់សិល្បៈកំណាព្យក៏ដូចជាទម្រង់សិល្បៈដទៃៗទៀត។ អត្ថបទកំណាព្យខ្វះរូបារម្មណ៍ វាមានតម្លៃត្រឹមតែជាអត្ថបទ

---

[១៥] ព្រះហរិរក្ខរាមាឥស្សរាធិបតី ព្រះអង្គ ឌួង : ***រឿងកាកី*** ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៦ ឆ្នាំ១៩៧៤ ទំព័រទី១៥-១៦។

ពាក្យចួនសោះកក្រោះប៉ុណ្ណោះ។

ដូចនេះស្នាដៃអក្សរសិល្ប៍ បើខ្វះរូបារម្មណ៍សិល្បៈ វាពុំអាចមានលក្ខណៈជាអក្សរសិល្ប៍ឡើយ។

**៣- វិធីបង្កើតរូបារម្មណ៍សិល្បៈក្នុងស្នាដៃអក្សរសិល្ប៍**

**តើរូបារម្មណ៍ទាំងឡាយក្នុងអត្ថបទអក្សរសិល្ប៍កើតឡើងដោយវិធីណា?**

ដើម្បីធ្វើឱ្យស្នាដៃរបស់ខ្លួនមានសម្មស្សរស់រវើក កវី អ្នកនិពន្ធ ត្រូវតែមានសិល្បវិធីតែងនិពន្ធខ្ពស់ ចេះធ្វើយ៉ាងណាឱ្យសិល្ប៍ប្រធានរបស់អ្នកអាន អ្នកស្ដាប់រំភើបជក់ចិត្ត ចាប់អារម្មណ៍ចំពោះស្នាដៃរបស់ខ្លួន។

ទាំងនេះជាវិធីសំខាន់ៗមួយចំនួន ដែលយើងបានរកឃើញក្នុងស្នាដៃនិពន្ធមួយចំនួនក្នុងការបង្កើតរូបារម្មណ៍សិល្បៈ ដូចជា៖

-**បច្ចេកវិធី** សំដៅទៅដល់បច្ចេកទេសក្នុងការរៀបចំសរសេរនៃស្នាដៃរឿងឬអត្ថបទផ្សេងៗ ដូចជា ប្រលោមលោក ច្បាប់ឧបទេស រឿងល្ខោន អត្ថបទស្រាវជ្រាវ ជាដើម។

តើអត្ថបទទាំងនោះ ត្រូវសរសេរជា***ពាក្យកាព្យ ពាក្យរាយ ឬពាក្យកម្រងកែវ?***

តើអត្ថបទទាំងនេះ វាមានលក្ខណៈជាប់ទាក់ទងទៅនឹងផ្នែកសំខាន់ៗនៃអរិយធម៌ (វប្បធម៌ សង្គមធម៌) បែបណាដែរ?

ជាទូទៅគ្រប់អត្ថបទទាំងនេះ យើងឃើញថា ច្រើនមានអត្ថន័យជាប់ទាក់ទងទៅនឹង៖

- ផ្នែកវប្បធម៌ មាន *ជំនឿ សាសនា ទស្សនវិជ្ជា សង្គមវិជ្ជា ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ ទំនៀមទម្លាប់ ប្រពៃណី ជាដើម។*
- ផ្នែកសង្គមធម៌ មាន៖
    - សង្គមសម្ភារៈ ជាគ្រឿងប្រដាប់ប្រដាសម្រាប់បង្កើតផលិតផលនៃសម័យកាលរបស់រឿង ដូចជា *គ្រឿងឧបករណ៍ប្រើប្រាស់ របររកស៊ី ជាដើម។*
    - សង្គមវិធី ជាវិធីបង្កើតផលិតផលឬទស្សនវិធីចែកផលិតផល ដូចជា *សេដ្ឋកិច្ច សង្គមកិច្ច(ការរស់នៅ ការគ្រប់គ្រង) នយោបាយ ជាដើម។*
    - ទំនាក់ទំនងសង្គម មាន*ញាតិ គ្រួសារ សហគមន៍ ឋានៈ ស្ថាប័ន រដ្ឋ ជាដើម។*

-**វចនវិធី** វិធីប្រើពាក្យពេចន៍របស់កវី អ្នកនិពន្ធក្នុងអត្ថបទរបស់ខ្លួន ដូចជា៖

- អត្ថបទបែបព្រាហ្មណ៍និយម កវី អ្នកនិពន្ធច្រើនប្រើពាក្យពេចន៍ដែលក្លាយមកពីភាសាសំស្ក្រឹត ដូចជាអត្ថបទ *រឿងរាមកេរ្តិ៍* ជាដើម។
- អត្ថបទបែបពុទ្ធនិយម កវី អ្នកនិពន្ធច្រើនប្រើពាក្យបាលី ដូចជាអត្ថបទ *រឿងទសជាតក បញ្ញាសជាតក* ជាដើម។

- អត្ថបទបែបខេមរនិយម កវី អ្នកនិពន្ធ ច្រើនប្រើពាក្យខ្មែរសាមញ្ញៗ ពាក្យខ្មែរសម័យទំនើប ពាក្យខ្មែរតាមតំបន់ ដែលធ្វើឱ្យអ្នកអានគ្រប់លំដាប់ថ្នាក់អាចឆាប់យល់ន័យបាន ដូចជា *រឿងព្រេងប្រជាប្រិយ ប្រលោមលោកទំនើប ជាដើម។*

ជារួម វចនវិធី គឺជាវិធីដែលកវី អ្នកនិពន្ធចេះជ្រើសរើសយកពាក្យពេចន៍មកប្រើក្នុងអត្ថបទឱ្យបានពីរោះ មានខ្លឹមសារ អាចបង្ហាញនូវមតិ គំនិត ទស្សនៈ វត្ថុបំណងក្នុងផ្នែកអត្ថន័យថែមទៀតផង។ និយាយរួមវចនវិធី ដែលល្អគឺ កវី អ្នកនិពន្ធត្រូវចេះប្រើពាក្យពេចន៍ឱ្យត្រូវទៅតាមការពិតជាក់ស្ដែង។ ឧទាហរណ៍ នៅក្នុងអត្ថបទពាក្យកាព្យ កវីត្រូវប្រើពាក្យពីរោះណែងណង ល្ហងល្ហាយ ធ្វើឱ្យអារម្មណ៍អ្នកអានរំភើប អណ្ដែត សង្វេគបាន។ ចំណែកក្នុងអត្ថបទប្រលោមលោក អ្នកនិពន្ធត្រូវចេះប្រើពាក្យពេចន៍ឱ្យស្របទៅនឹងប្រធានរឿងក្នុងអត្ថន័យទៅតាមលក្ខណៈតួអង្គ ទៅតាមវណ្ណៈសង្គម នៃស្នាដៃប្រលោមលោកនោះ ជាក់ស្ដែងដូចជា ៖

  - o តួអង្គអ្នកក្រ  ត្រូវនិយាយពាក្យសម្ដីបែបអ្នកក្រ
  - o តួអង្គអ្នកមាន អ្នកជំនួញ ត្រូវនិយាយពាក្យសម្ដីបែបអ្នកមាន អ្នកជំនួញ
  - o អ្នកធំ អ្នករាជការ ត្រូវនិយាយបែបអ្នកធំ អ្នករាជការ ជាដើម។

• **រចនាវិធី** វិធីផ្សេងៗសម្រាប់តែងនិពន្ធ ដើម្បីធ្វើឱ្យអត្ថបទមានសម្រស់និងបង្កើតបាននូវសិល្បបរិយាកាសមួយ ដែលអាចនាំឱ្យអ្នកអានមានអារម្មណ៍អណ្ដែតអណ្ដូង ត្រិះរិះពិចារណា សប្បាយ សង្វេគ ព្រួយបារម្ភ ភ្ញាក់ស្មារតី ជាដើម។

វិធីផ្សេងៗដែលកវី អ្នកនិពន្ធធ្លាប់ប្រើមាន៖

❖ **ឧបមានវិធី** ជាវិធីពិសេសមួយក្នុងការបង្កើតរូបារម្មណ៍សិល្បៈក្នុងស្នាដៃកំណាព្យ ស្នាដៃប្រលោមលោក ជាដើម។ វិធីនេះអាចចែកចេញជា៖

- ឧបមានវិធីដោយពុំប្រើបច្ច័យធៀប(ជីវរូបារម្មណ៍វិធី) កវី អ្នកនិពន្ធប្រើពាក្យពេចន៍ក្នុងការផ្គូផ្គងយ៉ាងណារំលេចឱ្យឃើញអង្គមួយឥតជីវិត ឥតចេតនា ឥតចលនា ឥតវិញ្ញាណ អង្គអរូបី ឱ្យមានជីវិត មានចេតនា មានចលនា មានវិញ្ញាណ មានរូបឡើង។

ឧទាហរណ៍ *ខ្យល់ត្អូញឆ្លងឆ្លើយ សម្ដីផ្អែម ចិត្តទន់ ចិត្តរឹង ... ។*

- ឧបមានវិធីប្រើពាក្យបច្ច័យធៀបមាន *រូ រូបហាន ដូច ដូចជា ប្រៀបបាន ដូចនឹង ប្រដូច ... ។*

ឧទាហរណ៍ [...] មកយល់វាលវែងត្រែងដូលដុះ  ផ្កាសត្រសុសផ្លេកភ្លឺថ្លា
ដូចរូបសម្បុរពណ៌កនិដ្ឋា  ដូចផ្កាត្រែងត្រស់ស្រណោះពេក។
មៀងមើលទឹកជ្រៅស្មៅត្រកៀត ចិត្តបងចង្អៀតរឹងរិវេគ

ត្រកួនជ្រួបខ្លួនបងឈប់ដេក ឈប់ដោយម្លប់មែកត្របែកព្រៃ[១៦]។[...]

❖ **បុនរុត្តិវិធី** វិធីតែងនិពន្ធ ដែលកវី អ្នកនិពន្ធប្រើក្នុងការនិពន្ធរឿង ដោយធ្វើឱ្យកើតមាននូវសភាពផ្ទួនដដែលៗ។ វិធីតែងនិពន្ធបែបនេះច្រើនប្រើក្នុងអត្ថបទកាព្យ។ វិធីផ្ទួនក្នុងបុនរុត្តិវិធីមានបួនលក្ខណៈ៖

- វិធីប្រើស្រៈឬព្យញ្ជនៈមានសំឡេងផ្ទួនគ្នា
- វិធីផ្ទួនពាក្យដើម្បីសម្គាល់លក្ខណៈ គុណភាពដោយប្រើគុណនាមផ្ទួនគ្នា
- វិធីផ្ទួនពាក្យដើម្បីសម្គាល់នូវសកម្មភាពឬចលនា
- វិធីផ្ទួនគំនិតនិងបញ្ហាដដែលៗ

❖ ***វេសម្មវិធី*** វិធីតែងនិពន្ធ ដែលកវី អ្នកនិពន្ធលើកយកគុណភាពពីរ ចលនាឬសកម្មភាពពីរ គំនិត ទស្សនៈពីរ អត្តខាងក្នុងនិងខាងក្រៅរបស់តួអង្គណាមួយ ដែលប្លែកគ្នាផ្ទុយគ្នាឱ្យស្ថិតនៅជាប់គ្នា ដើម្បីបង្ហាញកាន់តែច្បាស់ឬបង្ហាញនូវប្រយោជន៍អ្វីមួយ។

វេសម្មវិធីអាចធ្វើទៅបានដោយ៖

- **វិធីផ្ទុយពណ៌សម្បុរ** វិធីនេះច្រើនប្រើក្នុងការបង្ហាញចក្ខុឬកាយរូបារម្មណ៍។

ឧទាហរណ៍ ក្នុង ***រឿងរាមកេរ្តិ៍*** ខ្សែទី១ ទំព័រទី៥១ ការពិពណ៌នាអំពីកូខ័ន

*[...] សក្តិសួនជាអ្នកថ្មើរព្រៃ ខ្លួន**ខ្មៅ**ក្រៅវិស័យ នូវធ្មេញ**សស្គឹម**ភ្នែកច្រាល។[...]*

- **វិធីផ្ទុយរូបភាព** វិធីនេះប្រើដើម្បីរំលេចឱ្យឃើញអំពីភាពខុសគ្នារវាងផ្លូវកាយនិងលក្ខណៈផ្លូវចិត្តរបស់តួអង្គ ដូចជា តួអង្គមានលក្ខណៈកាយល្អ តែចិត្តអាក្រក់ ជាដើម។

ឧទាហរណ៍ - នាងកាកី មានរូបសម្បត្តិល្អ តែមានចិត្តក្បត់ប្តី។

- កូខ័ន មានរូបអាក្រក់ តែចិត្តល្អបរិសុទ្ធ។

- **វិធីផ្ទុយហេតុនិងផល** វិធីនេះប្រើបង្ហាញអំពីដំណើររឿងនៃទំនាស់វិបត្តិដែលកើតឡើងដោយមានភាពមិនស្របគ្នារវាងបញ្ហានិងលទ្ធផលនៃទំនាស់។ការបង្ហាញភាពផ្ទុយនៅត្រង់ ***ហេតុតូចឬតិចសោះ តែផលទៅជាធំសម្បើម*** ជួនកាល ***ហេតុធំសម្បើម តែផលសឹងតែគ្មាន***។

▫ ***ហេតុតូចឬតិចសោះ តែផលបែរទៅជាធំសម្បើម***

ឧទាហរណ៍ ក្នុងរឿង ***រាមកេរ្តិ៍*** ខ្សែទី៦ ទំព័រទី៤៧ ត្រង់វគ្គ ហនុមានច្បាំងជាមួយយក្សអតិកាយ។ អតិកាយបានប្រែកាឡាខ្លួនធំដល់មេឃ តែហនុមានលោតទៅធាក់តែមួយជើង អតិកាយដាច់ផ្ទារប៉ាយដួលទៅដី។

---

[១៦] ព្រះបទុមត្ថេរ សោម : ***រឿងទុំទាវ*** ជ.ឯ.ម. ទំព័រទី៣៩។

▫ ***ហេតុធំសម្បើម តែផលសឹងតែគ្មាន***

ឧទាហរណ៍ ក្នុង***រឿងរាមកេរ្តិ៍*** ខ្សែទី៤ ទំព័រ៥៦ ត្រង់ពាលីច្បាំងនឹងទូភី ម្នាក់ៗសុទ្ធមានតេជៈបារមីខ្លាំងពូកែ មានគ្រឿងសព្វាវុធដ៏វិសេស ប៉ុន្តែ ច្បាំងគ្នាមិនឈ្នះ មិនចាញ់។ បានសេចក្តីថា ការប្រយុទ្ធខ្លាំង តែលទ្ធផលបែរជាគ្មានសោះ។

-**វិធីធ្វើឱ្យផលប្លែកពីហេតុ** វិធីនេះប្រើដើម្បីបង្ហាញហេតុការណ៍ណាមួយ ដែលគេអាចសន្និដ្ឋានឬយល់បានថា វាដូចនេះ ដូចនោះ តែផលមិនមែនដូចការគិតនិងយល់របស់យើងពីដំបូងឡើយ។

ឧទាហរណ៍ ក្នុងអត្ថបទកំណាព្យ***តុកកាមកិលេស***របស់លោក កេង វ៉ាន់សាក់ ទំព័រ២៦ *[...] មិនដឹងពេលម៉ោង មើលតាមប្រហោង ឃើញតាមគំនិត មេឃាធំធេង ល្ងឹងល្ងើយដូចចិត្ត មានសេរីសិទ្ធិ៍ តាមតែបំណង។[...]*

- **វិធីផ្ទុយចលនា** វិធីនេះប្រើក្នុងការបង្ហាញនូវចលនានៃដំណើរវិវត្តិប្រែប្រួលរបស់ធម្មជាតិ ដែលមិនចំណុះឱ្យញាណឬមនោរបស់មនុស្សដែលមិនចង់បានការប្រែប្រួល។

-**វិធីផ្ទុយមតិ ពិចារណា** វិធីនេះប្រើដើម្បីបង្ហាញឱ្យឃើញនូវសភាពផ្ទុយនៃគំនិត មតិការពិចារណា ដែលកើតមានចំពោះមនុស្ស ដូចជា ពេលខ្លួនចាស់ នឹកឃើញការសប្បាយកាលពីក្មេង តែមិនអាចវិលទៅរកសភាពដើមវិញ។

❖ **វឌ្ឍមានវិធី** ជាវិធីតែងនិពន្ធ ដែលកវី អ្នកនិពន្ធធ្វើឱ្យដំណើររឿងមានការប្រែប្រួលពីធូរស្រាលទៅតានតឹងឬពីតានតឹងទៅធូរស្រាល។

ឧទាហរណ៍ ក្នុង***រឿងទុំទាវ*** ស្នេហាទុំទាវចេញដំណើរពីសភាពធម្មតាទៅរកភាពតានតឹងឡើងៗ រហូតដល់តួអង្គទុំនិងទាវស្លាប់នៅទីបញ្ចប់នៃរឿង។

ក្នុង***រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់*** ដំណើរជីវិតរបស់តួអង្គសម ចេញពីសភាពតានតឹងនៅខាងដើមរឿង។ ប៉ុន្តែ នៅខាងចុងនៃរឿងជីវិតរបស់គាត់មានសភាពធូរស្រាលបន្តិចម្តងៗ រហូតដល់ធូរស្រាលមែនទែន។

❖ **សន្ទេហវិធី** ជាវិធីតែងនិពន្ធ ដែលកវី អ្នកនិពន្ធចេះធ្វើឱ្យអ្នកអាន អ្នកស្តាប់ ជក់អារម្មណ៍ចង់ដឹង ចង់តាមដានដំណើររឿង តាមរយៈការបង្កើតនាដ្យខណៈ ការបង្ហាញហេតុនិងចិត្តសង្ស័យ។

❖ **សំវាទវិធី** ជាវិធីតែងនិពន្ធ ដែលកវី អ្នកនិពន្ធធ្វើឱ្យតួអង្គជជែកសន្ទនា ឆ្លើយឆ្លងទៅវិញទៅមក។

ឧទាហរណ៍ នៅក្នុងអត្ថបទកំណាព្យ ***ល្បើកជុចនិងត្រី*** របស់ប្លាងវិសសអក្ខរា ដូង

*[...] ថ្លែងដោយទំនង ដំណើរត្រីផងយាត្រា ពើបនឹងដុចណា ត្រីស្រែកថារ៉ីយចៀសចេញ ។*

*ដុចថាអីអើ បទអ្នកនេះតើម្ដេចមិញ ក៏មកប្រើអញ ចៀសចេញឱ្យអ្នកជាល្បែង ។ [...]*

❖ **ឯកវាទវិធី** ជាវិធីតែងនិពន្ធ ដែលកវី អ្នកនិពន្ធធ្វើឱ្យតួអង្គសញ្ជឹងគិត ពិចារណា ថ្លែងពីការសប្បាយ ទុក្ខព្រួយ ឬ រៀបរាប់ពីអនុស្សាវរីយ៍អ្វីមួយតែម្នាក់ឯង ។

ឧទាហរណ៍ ក្នុង***រឿងភូមិតិរច្ឆាន***នៃលោក ឌឹក គាម និង ឡៅ ក អំ ទំព័រទី៣៧ មេឃុំប៉ាល់ពេល ទទួលបញ្ជាឱ្យទារពន្ធពីប្រជារាស្ត្រ គាត់បានគិតម្នាក់ឯងថា៖

*[...] «ណាមួយខ្លួនឯងកាន់តែចាស់ជរាណាស់ទៅហើយ មិនបានកាន់សីលប្រាំចាំសីលប្រាំបី ជាប់លាប់នឹងគេ ព្រោះរវល់តែពីរឿងកិច្ចការរាជការមមាញឹក ណាមួយនឹកមួរម៉ៅក្ដៅក្រហាយ ទារពន្ធមិនបាន ណាមួយជួយអាណិតអាសូរកូនឃុំ» ។ [...]*

❖ **វណ្ណនាវិធី** វិធីតែងនិពន្ធ ដែលកវី អ្នកនិពន្ធប្រើក្នុងការនិពន្ធរឿង អត្ថបទ ដោយរៀបរាប់ ពណ៌នាអំពីសកម្មភាពរបស់តួអង្គ រឿងរ៉ាវផ្សេងៗ ទេសភាពឬធម្មជាតិ ឱ្យឃើញច្បាស់ដូចបានឃើញនឹងភ្នែកស្រស់ៗ ។

**សម្គាល់** វណ្ណនាវិធីដែលល្អ កវី អ្នកនិពន្ធត្រូវចេះរៀបរាប់សេចក្ដីឱ្យតិច ខ្លី ប៉ុន្តែ ច្បាស់លាស់ កុំឱ្យមានសេចក្ដីច្រំដែល កុំឱ្យមានគំនិតនិងពាក្យពេចន៍ដដែលៗ ។

ឧទាហរណ៍ ការពណ៌នារបស់អ្នកនិពន្ធ នូ ហាច នៅក្នុងរឿងផ្កាស្រពោន

*[...] រទេះភ្លើងបោលលឿនដូចព្យុះកាត់ព្រៃខ្លុងនិងព្រេច រត់ឆ្លងអូរ ហើយជ្រែកពុះជើងភ្នំ ដោយបញ្ចេញសន្ធឹកខ្ទរំពង ធ្វើឱ្យរញ្ជួយផែនពសុធា ។ បន្តិចក្រោយមក យាននោះ ក៏បើកផុតជួរភ្នំនិងព្រៃស្ងាត់អស់ ហើយបើប្រសិនជាគេអើតមើលតាមបង្អួចនៃទូណាមួយទៅ គេនឹងឃើញវាលស្រែដ៏មានភ្លឺខ្មៅប្រផេះ ខ្វែងកាត់ជាក្រឡាចត្រង្គ ប្រកបដោយកិរិយាចេះរត់ថយក្រោយវិញ ។ ... នៅក្នុងស្រែសុទ្ធតែមានទឹកសស្វាច ពេញព្រៀប ដែលខ្យល់រំហើយបោកបក់បណ្ដាលឱ្យកើតជារលកពព្រាំមកយោលដើមស្រូវខ្ចី ពណ៌បៃតងស្រស់ ។ [...]*

❖ **ឧបកថាវិធី** ជាវិធីតែងនិពន្ធ ដែលកវី អ្នកនិពន្ធប្រើក្នុងការតែងរឿង ដោយរៀបរាប់ពីព្រឹត្តិការណ៍នៃបញ្ហាមួយមិនទាន់ចប់សេចក្ដីផង ស្រាប់តែផ្អាកមួយខណៈ រួចក៏លើកយកព្រឹត្តិការណ៍នៃបញ្ហាថ្មីមួយទៀតមកនិយាយបន្ត ។

ឧទាហរណ៍ ក្នុងរឿងរាមកេរ្តិ៍ ខ្សែទី៤ ដើមដំបូងអ្នកនិពន្ធនិយាយពីដំណើរព្រះរាមត្រាច់ចររកនាងសីតា បន្ទាប់ពីក្រុងរាពណ៍ចាប់យកទៅ។ ដំណើររឿងនេះមិនបានដឹងសេចក្ដីអស់ផង អ្នកនិពន្ធក៏ចាប់លើកយកដំណើររឿងស្ដេចក្របីឈ្មោះទូភីបង្កចម្បាំងជាមួយស្ដេចស្វាឈ្មោះពាលីទៅវិញ ។

ជារួមសិល្បវិធីតែងនិពន្ធមួយចំនួនដូចបានលើកឡើងខាងលើនេះ ជាមធ្យោបាយដ៏សំខាន់ក្នុងការបង្កើតរូបារម្មណ៍សិល្បៈក្នុងស្នាដៃអក្សរសិល្ប៍។ ការបង្កើតរូបារម្មណ៍សិល្បៈអ្នកនិពន្ធត្រូវពឹងផ្អែកលើវិធីផ្សេងៗជាច្រើន ពិសេសការប្រើពាក្យពេចន៍ក្នុងការពិពណ៌នាហេតុការណ៍ ធម្មជាតិ រូបរាង ជាដើម។ បើការប្រើពាក្យពេចន៍មិនល្អទេ នោះអ្នកអានអ្នកស្តាប់ក៏មិនអាចទទួលខ្លឹមសារបានដែរ។

## សន្និដ្ឋាន

សរុបមកការបង្កើតអត្ថបទអក្សរសិល្ប៍បានល្អ ឆ្លើយតបទៅនឹងសំណូមពរនៃការចង់ចេះ ចង់ដឹងរបស់អ្នកអាន អ្នកស្តាប់ ទាំងអត្ថន័យនិងអត្ថរូបនៃស្នាដៃត្រូវតែល្អដូចគ្នា។ ដើម្បីឱ្យស្នាដៃរបស់ខ្លួនមានសម្ផស្សរស់រវើកនិងមានតម្លៃផងនោះ ចាំបាច់អ្នកនិពន្ធត្រូវតែមានទេពកោសល្យខ្ពស់ ចេះធ្វើឱ្យអារម្មណ៍អ្នកអាន អ្នកស្តាប់ ចូលក្នុងដំណើររឿងជាមួយនឹងតួអង្គរបស់គាត់ដែរ។

ក្នុងការបង្កើតរូបារម្មណ៍សិល្បៈក្នុងស្នាដៃអក្សរសិល្ប៍ អ្នកនិពន្ធអាចមានល្បិចវិធីច្រើនក្នុងការសរសេរ តែយើងមិនត្រូវគិតថា មានតែវិធីនេះល្អជាងវិធីនោះទេ។ នៅគ្រប់ល្បិចវិធីទាំងអស់សុទ្ធតែមានសារៈសំខាន់ក្នុងការចាប់ឆក់យកអារម្មណ៍អ្នកអាន អ្នកស្តាប់ ដូចគ្នា។ប៉ុន្តែការសិក្សាអំពីរូបារម្មណ៍សិល្បៈនេះ យើងបង្ហាញតែវិធីតែងនិពន្ធមួយចំនួនតែប៉ុណ្ណោះក្នុងការបង្កើតរូបារម្មណ៍ ដើម្បីបញ្ជាក់ថា ពុំមែនមានតែឧបមានវិធីតែមួយ ដែលសំខាន់ជាងគេ ហើយទាត់ចោលនូវវិធីផ្សេងទៀតនោះ។

ដូចនេះ ដើម្បីឆ្លើយតបនឹងមុខងារពុទ្ធិ មុខងារអប់រំ ការបង្កើតស្នាដៃអក្សរសិល្ប៍ត្រូវៈ

- ឆ្លុះបញ្ចាំងសារជាតិនិងក្រឹត្យក្រមតថភាពជាក់ស្តែងនៃសង្គមឱ្យស្របតាមសច្ចភាពជីវិតពិតៗ។ ការឆ្លុះបញ្ចាំងត្រូវតែប្រព្រឹត្តទៅតាមលក្ខណៈសច្ចៈត្រឹមត្រូវ ចៀសវាងការភូតភរកុហក បំផ្លើសការពិត។

- ឆ្លុះបញ្ចាំងទិដ្ឋភាពសំណូមពរចាំបាច់នៃជីវិត។ ក្នុងក្របខណ្ឌនៃសង្គមញ្ញាណ ស្នាដៃអក្សរសិល្ប៍ មិនគ្រាន់តែមានភារកិច្ចឆ្លុះបញ្ចាំងសង្គមប៉ុណ្ណោះទេ តែវាថែមទាំងបំពេញតួនាទីក្នុងការកែប្រែសង្គមទៀតផង។

- ចេះប្រើវិធីរៀបរាប់ឱ្យរស់រវើកតាមរយៈវិធីបង្កើតរូបារម្មណ៍សិល្បៈ។ បានន័យថាការឆ្លុះបញ្ចាំងត្រូវឱ្យមានលក្ខណៈឯកភាពគ្នារវាងសច្ចភាពជីវិត និងសច្ចភាពសិល្បៈ។

# ឯកសារពិគ្រោះ


- ពៅ សាមី : ***មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍និងសិល្បវិជ្ជា*** *ភាគ១ ២ ៣* ភ្នំពេញ, គ្រឹះស្ថានបោះពុម្ពសុភមង្គល ឆ្នាំ២០១២។
- នូ ហាច : ***រឿងផ្កាស្រពោន*** ភ្នំពេញ, អាគារបោះពុម្ពផ្សាយវប្បធម៌ បោះពុម្ពលើកទី១ ឆ្នាំ១៩៨៩។
- លាង ហាប់អាន : ***សិក្សាអត្ថបទ*** *ភាគ២* ភ្នំពេញ, រោងពុម្ព [?] ឆ្នាំ១៩៦៦។
- លី សុមុនី : ***កំណាព្យខ្មែរ*** ភ្នំពេញ, បោះពុម្ពឡើងវិញដោយ គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៃក្រសួងអប់រំ យុវជន និង កីឡា, ឆ្នាំ២០០៩។
- សោម សុមុនី : ***វិភាគទានក្នុងការសិក្សាអក្សរសិល្ប៍ខ្មែរ*** ភ្នំពេញ, រោងពុម្ពម៉េងហាវ ឆ្នាំ២០១៥។
- សទ្ទានុក្រម : ***ភាសាវិទ្យានិងអក្សរសិល្ប៍*** ខ្មែរ-អង់គ្លេស-បារាំង, ភ្នំពេញ, បោះពុម្ពដោយក្រុមប្រឹក្សាជាតិភាសាខ្មែរ ឆ្នាំ២០១៣។
- ព្រះហរិរក្ខរាមាឥស្សរាធិបតី ព្រះអង្គ ឌួង: ***រឿងកាកី*** ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៦ ឆ្នាំ១៩៧៤។
- ព្រះបទុមត្ថេរ សោម : ***រឿងទុំទាវ*** ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកទី៧ ឆ្នាំ១៩៧១។
- *ព្រឹត្តិប័ត្រស្រាវជ្រាវវិទ្យាសាស្ត្រ* លេខ២ ភ្នំពេញ, ឆ្នាំ១៩៨៧។
- *ព្រឹត្តិប័ត្រស្រាវជ្រាវវិទ្យាសាស្ត្រ* លេខ៤ ភ្នំពេញ, ឆ្នាំ១៩៨៧។